គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា

**CAMBODIAN HUMAN RIGHTS ACTION COMMITTEE**

ADHOC - CARAM Cambodia - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP- IDA
KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC - OUTREACH – PDP - PJJ - TASK FORCE - VIGILANCE
#09, St 330, Sangkat Boeung Keng Kang3, Khan Chamcar Mon, Phnom Penh, Cambodia, Tel/Fax: 023 301 415 E-mail: chrac@forum.org.kh


# សេចក្តីប្រកាសព័ត៌មាន

## គណៈកម្មាធិការប្រព្រឹត្តិកម្មទទួចសុំឱ្យអង្គជំនុំជម្រះវិសាមញ្ញគិតគូរអំពី សិទ្ធិរបស់ជនរងគ្រោះដោយការយកចិត្តទុកដាក់

*ភ្នំពេញ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០*

នៅក្នុងកំឡុងពេល នៃកិច្ចប្រជុំពេញអង្គចៅក្រម ពីថ្ងៃទី០២ ដល់ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ ខាងមុខនេះ សមាជិកកិច្ចប្រជុំពេញអង្គ នឹងធ្វើវិសោធនកម្មទៅលើវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) ជាពិសេសទៅលើបទប្បញ្ញត្តិទាក់ទិននឹងការចូលរួមរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឱ្យមានដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាព នៅក្នុងសំណុំរឿង០០២ និង ដែលជាសំណុំរឿងសំខាន់ផងដែរ។ នៅក្នុងឱកាសដែលមានការធ្វើវិសោធនកម្មដោយកិច្ចប្រជុំពេញអង្គនាពេលនេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ដែលជាសម្ព័ន្ធនៃអង្គការសមាគមដែលមានសមាជិកចំនួន ២១ បំរើការងារលើវិស័យសិទ្ធិមនុស្ស ផ្តល់ជំនួយផ្នែកច្បាប់ និងលើកស្ទួយលទ្ធិប្រជាធិបតេយ្យ នៅក្នុងប្រទេសកម្ពុជា សូមទទូចសុំឱ្យ លោក លោកស្រី ចៅក្រម មេត្តាគិតគូរពិចារណាដោយយកចិត្តទុកដាក់ទៅលើសំណើសុំធ្វើវិសោធនកម្ម (ដូចដែលបានឃើញនៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះវិសាមញ្ញ កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ ស្រាប់) នៅខណៈពេលដែលខិតខំធ្វើឱ្យមានសមតុល្យប្រកបដោយមានត្រឹមត្រូវ និងយុត្តិធម៌រវាងការចង់ធានាឱ្យមានដំណើរការខាងផ្លូវច្បាប់ប្រកបដោយប្រសិទ្ធិភាព និង សិទ្ធិរបស់ជនរងគ្រោះ។

ចាប់តាំងពីឆ្នាំ២០០៧ មក អង្គការអន្តរការី ដែលជាសមាជិករបស់គណៈកម្មាធិការប្រព្រឹត្តិកម្ម បានជួយជនរងគ្រោះ ប្រមាណ ៤,៥០០ នាក់ ក្នុងការដាក់ពាក្យបណ្តឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅកាន់តុលាការ ដែលនេះ សបញ្ជាក់ឱ្យឃើញច្បាស់ថា វាពិតជាមាននូវការចាប់អារម្មណ៍ជាខ្លាំង និងសេចក្តីប្រាថ្នារបស់ជនរងគ្រោះក្នុងការចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនីតិវិធីផ្លូវច្បាប់ និង ប្រើប្រាស់ដោយពេញលេញនូវសិទ្ធិដែលបានផ្តល់ដល់គេ ដោយលោក លោកស្រី ចៅក្រម តាមរយៈការចែងនៅក្នុងវិធានផ្ទៃក្នុង ដោយស្របទៅតាមច្បាប់ជាតិរបស់ព្រះរាជណាចក្រកម្ពុជាផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ កង្វះ និង ភាពយឺតនៃព័ត៌មានអំពីដែនស៊ើបអង្កេតរបស់តុលាការទាក់ទិននឹងគោលនយោបាយទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី អាចបណ្តាលឱ្យមានអ្នកដាក់ពាក្យសុំតាំងខ្លួនជាច្រើននាក់សំរាប់សំណុំរឿង ០០២ មិនត្រូវបានទទួលស្គាល់។ ការណ៍នេះ វាបានធ្វើឱ្យមានភាពមិនពេញចិត្តរួចទៅហើយ ពីសំណាក់អ្នកដាក់ពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់។ ដូចនេះ

អ្វីដែលជាកិច្ចការសំខាន់ គឺថា គួរតែនៅពេលកិច្ចប្រជុំពេញអង្គនាពេលនេះ ពិភាក្សាទៅលើអនាគតតួនាទីរបស់ជនរងគ្រោះដោយភាពប្រុងប្រយ័ត្ន ភាពស្មោះត្រង់ និងគោរពចំពោះសិទ្ធិរបស់គេ។

នៅក្នុងបរិបទនេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម ក៏ដូចជា អង្គការដទៃផ្សេងទៀត បានដាក់បញ្ជូនរួចរាល់ហើយនូវអនុសាសន៍/យោបល់ទៅលើវិសោធនកម្មដែលបានស្នើឡើង ទៅកាន់គណៈកម្មាធិការវិធានផ្ទៃក្នុង និងនីតិវិធី ក៏ដូចជាទៅកាន់កិច្ចប្រជុំពេញអង្គចៅក្រម ដោយមានចំណុចសំខាន់ៗមួយចំនួន ដូចតទៅនេះ

ទីមួយ គឺថា គណៈកម្មាធិការប្រព្រឹត្តិកម្ម កត់សំគាល់ឃើញថា វាមានចំណុចវិវត្តន៍វិជ្ជមានជាច្រើន។ ជាពិសេស យើងក៏សូមអបអរសាទរចំពោះការពង្រីកនូវអាណត្តិរបស់អង្គភាពជនរងគ្រោះ ដើម្បីឱ្យអាចបង្កើត និងអនុវត្តន៍នូវកម្មវិធីផ្សេងៗ និងវិធានមិនមែនផ្លូវច្បាប់ដទៃផ្សេងទៀត ដើម្បីឆ្លើយតបទៅនឹងផលប្រយោជន៍របស់ជនរងគ្រោះបានកាន់តែទូលំទូលាយជាងមុនថែមទៀត។ ការណ៍នេះ នឹងត្រូវការឱ្យមានការយុទ្ធសាស្ត្របែបពិគ្រោះពិភាក្សា និងសហប្រតិបត្តិការមួយនៅក្នុងការរៀបចំនូវវិធានការទាំងនេះ ព្រមជាមួយនឹងការរៀបចំនានាសំរាប់បែបបទរដ្ឋបាល និងថវិកា ដើម្បីធានាឱ្យមានការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៀត យើងក៏ឃើញ មានការស្នើឡើងនូវកំណើនដែលធ្លាប់ត្រូវបានទាមទារឱ្យមានអស់រយៈពេលដ៏យូរ នៃ កំរិតថវិកា ដែលផ្តល់ដោយតុលាការទៅលើការតំណាងតាមផ្លូវច្បាប់សំរាប់ដើមបណ្តឹងរដ្ឋប្បវេណី ផងដែរ។ នៅក្នុងន័យនេះ យើងសូមទទូចសុំដល់តុលាការ និងម្ចាស់ជំនួយ មេត្តាផ្តល់នូវធនធានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ ដើម្បីធានាឱ្យមានការតំណាងតាមផ្លូវច្បាប់នូវផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីប្រកបដោយភាពឆ្លាតវៃ និងសមស្រប នៅគ្រប់តំណាក់កាលទាំងអស់ នៃដំណើរការនីតិវិធីផ្លូវច្បាប់។

ទីពីរ នៅក្នុងសំណើវិសោធនកម្មដែលបានកំពុងត្រូវគិតគូរពិចារណា ក៏ដាក់ចេញផងដែរនូវ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងតំណាងឱ្យក្រុមរួមបញ្ចូលគ្នាតែមួយ នៃដើមបណ្តឹងរដ្ឋប្បវេណី។ ទោះបីជា ភាពលំអិតជាច្រើននៃក្របខណ្ឌសហមេធាវីនាំមុខនៅពេលអនាគត នឹងត្រូវថែងបន្ថែមក៏ដោយ ក៏ប៉ុន្តែនៅពេលនេះ យើងសូមអំពាវនាវដល់លោក លោកស្រី ចៅក្រម កុំកំរិតនូវតួនាទីរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលកំពុងតែមាន ឱ្យហួសពីអ្វីដែលចាំបាច់ ដើម្បីធានាឱ្យមានប្រសិទ្ធិភាពនៃសវនាការ និងគោរពទៅលើសិទ្ធិជាមូលដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឧ. ដូចជា សិទ្ធិក្នុងការជ្រើសរើសមេធាវីរបស់គេផងដែរ។ ចំពោះបញ្ហានេះ បទប្បបញ្ញត្តិ ជាច្រើនត្រូវការចាំបាច់ឱ្យមាន ដើម្បីធានាមាននូវយន្តការបែបសហប្រតិបត្តិការគ្នា រវាងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សំរាប់ជាផលប្រយោជន៍របស់កូនក្តីនៃមេធាវីទាំងនោះ ក៏ដូចជា ពហុភាពនៃទស្សនៈរបស់ជនរងគ្រោះដែលនឹងត្រូវតំណាងនៅក្នុងតុលាការផងដែរ។

ទីបី គណៈកម្មាធិការប្រព្រឹត្តិកម្មក៏មានក្តីបារម្ភជាខ្លាំងចំពោះការកំរិតដែលបានស្នើឡើងសំរាប់ការទាមទារសំណង មកត្រឹមជាការទាមទារតែមួយ និងដាក់បញ្ចូលគ្នា ដែលនឹងមានតែការផ្តល់សំណងតែមួយ។ យើងយល់ថា បទប្បញ្ញត្តិនេះ គឺជាការប្រមាថមើលងាយដល់ចរិតលក្ខណៈ និងទំហំនៃភាពឈឺចាប់របស់ជនរងគ្រោះ ពីព្រោះដោយបានបដិសេធនូវឱកាសរបស់ពួកគេក្នុងការបញ្ចេញនូវពហុភាពនៃភាពឈឺចាប់របស់គេ តាមរយៈមធ្យោបាយដែលមានន័យចំពោះគេ និង ក៏ជាទឡ្ហីករណ៍ដែលរារាំងលោក លោកស្រី ចៅក្រម មិនឱ្យសំរេចបាននូវលទ្ធផល

ត្រឹមត្រូវ និងយុត្តិធម៌សំរាប់ជនរងគ្រោះ ផងដែរ ។ នៅខណៈពេលដែលលោក លោកស្រី ចៅក្រម យល់ឃើញថា វាជាការសមស្របក្នុងការកំរិតនូវការចេញសំណង ដើម្បីជំរុញឱ្យមានប្រសិទ្ធភាពនោះ វាដូចជាមិនសមស្របទេ ក្នុងការកំរិតមិនឱ្យជនរងគ្រោះបញ្ចេញនូវភាពឈឺចាប់រងគ្រោះរបស់ដែលបានទទួលរង និង រារាំងគេមិនឱ្យបញ្ចេញ សំលេងលើកឡើងអំពីសំណងជូនដល់តុលាការនោះ ។

ដូចនេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមទទូចស្នើសុំដល់អង្គជំនុំជម្រះវិសាមញ្ញ ដូចខាងក្រោមៈ

១- ធានាថា កម្មវិធីនានាសំរាប់ជនរងគ្រោះ និងវិធានការមិនមែនតាមផ្លូវច្បាប់ដទៃទៀត ត្រូវបានរៀបចំ ឡើងតាមបែបចូលរួម និង ថា បទប្បញ្ញត្តិអំពីបែបរដ្ឋបាលចាំបាច់ និងរចនាសម្ព័ន្ធថវិកា ត្រូវតែមាន ដើម្បីជួយឱ្យមានការអនុវត្តន៍ប្រកបដោយប្រសិទ្ធិភាព ។

២- ធានាថា ក្របខណ្ឌជំនួយផ្នែកច្បាប់ដែលមានលក្ខណៈត្រឹមត្រូវសំរាប់ដើមបណ្តឹងរដ្ឋប្បវេណី មាន ធនធានគ្រប់គ្រាន់ ដើម្បីអាចឱ្យមានភាពតំណាងតាមផ្លូវច្បាប់ដ៏សមរម្យនូវផលប្រយោជន៍សំរាប់ ដើមបណ្តឹងរដ្ឋប្បវេណី នៅគ្រប់តំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីច្បាប់ ។

៣- ធានាថា តួនាទីរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានកំរិតឱ្យហួសពីអ្វីដែលចាំបាច់ ក្នុងការធានាឱ្យមានប្រសិទ្ធិភាពនៃសវនាការ ដោយត្រូវណែនាំឱ្យមានបទប្បញ្ញត្តិគ្រប់គ្រាន់សំរាប់ ធានាឱ្យមានយុទ្ធសាស្រ្តបែបសហប្រតិបត្តិការគ្នា រវាងអនាគតសហមេធាវីនាំមុខតំណាងដើមបណ្តឹង រដ្ឋប្បវេណី និង មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងដោយត្រូវយកចិត្តទុកដាក់ទៅលើសិទ្ធិ ជាមូលដ្ឋាន និង ផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ។

៤- ពន្យាការធ្វើវិសោធនកម្មទៅលើវិធានមួយចំនួនដែលទាក់ទិននឹងសំណង ទៅកិច្ចប្រជុំពេញអង្គលើក ក្រោយទៀត ដើម្បីទុកពេលវេលាឱ្យលោក លោកស្រី ចៅក្រម ធ្វើការពិចារណាឱ្យបានពេញលេញ នូវគោលនយោបាយអំពីសំណង និងការអនុវត្តន៍សំណង តាមរបៀបមួយដែលវៃឆ្លាត និង ដោយមាន ការពិភាក្សាជាមួយនឹងភាគីពាក់ព័ន្ធដទៃទៀត ផងដែរ ។

***<u>សំរាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងជាមួយៈ</u>***

| | | |
|---|---|---|
| លោក **ហង្ស ឆាយា** | ប្រធានសំរបសំរួល CHRAC និង នាយកប្រតិបត្តិ KID | ទូរស័ព្ទលេខៈ ០១២ ៨៦៥៩១០ |
| លោក **ធន សារាយ** | ប្រធានសមាគមអាដហុក | ទូរស័ព្ទលេខៈ ០១៦ ៨៨០ ៥០៩ |
| លោក **សុក សំអឿន** | នាយកប្រតិបត្តិអង្គការ CDP | ទូរស័ព្ទលេខៈ ០១២ ៩០១១៩៩ |
| លោក **រុន សារាយ** | នាយកប្រតិបត្តិអង្គការ LAC | ទូរស័ព្ទលេខៈ ០១២ ៨៣៨ ៣៤១ |